# ប្រាសាទត្រពាំងប្រើស

នៅក្នុងតំបន់ការពារធម្មជាតិព្រៃឡង់មានប្រាសាទចំនួន០៥ ត្រូវបានចុះបញ្ជីសារពើភណ្ឌ ដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រួមមាន៖ ប្រាសាទត្រពាំងប្រើស ប្រាសាទស្ទឹងអន ប្រាសាទកំណប់សេអារ្យ និងប្រាសាទកំណប់នាងពៅ ស្ថិតនៅក្នុងទឹកដីខេត្ត កំពង់ធំ និងប្រាសាទបន្ទាយសៀមកាត់សក់ ស្ថិតនៅក្នុងទឹកដីខេត្តក្រចេះ។ សម្រាប់អត្ថបទខ្ញីនេះ ខ្ញុំសូមរៀបរាប់តែប្រាសាទត្រពាំងប្រើសមួយប៉ុណ្ណោះ ដោយសារប្រាសាទនេះមានស្ថានភាពល្អនៅឡើយ រីឯប្រាសាទផ្សេងទៀតបានបាក់រលំស្ទើរតែទាំងស្រុង។

ប្រាសាទត្រពាំងប្រើស មានទីតាំងស្ថិតនៅតំបន់ភ្នំជី ក្នុងភូមិតាយ៉ង ឃុំសុចិត្រ ស្រុកសណ្ដាន់ ខេត្តកំពង់ធំដែលមានចម្ងាយប្រមាណ ១៦០គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ធំ ហើយស្ថិតនៅត្រង់ និយាមកាលេខ WGS84-569727, 1421620។ ដើម្បីធ្វើដំណើរទៅប្រាសាទនេះបាន យើងត្រូវធ្វើដំណើរចេញពីទីរួមខេត្តកំពង់ធំឆ្ពោះទៅទីប្រជុំជន ឃុំទំរីង នៃស្រុកសណ្ដាន់ ដោយបន្តដំណើរទៅដល់ឃុំសុចិត្រ និងបន្តដំណើរទៅមុខទៀតដោយជិះម៉ូតូចូលក្នុងព្រៃជ្រៅប្រមាណ១៥គីឡូម៉ែត្រទើបដល់ប្រាសាទនេះ។ ម្យ៉ាងទៀតផ្លូវធ្វើដំណើរទៅដល់ប្រាសាទនេះ មានការលំបាកខ្លាំងណាស់ ជាពិសេសនៅរដូវវស្សា ដោយយើងចាំបាច់ត្រូវមានអ្នកភូមិជាអ្នកនាំផ្លូវជៀសវៀងការវង្វេងក្នុងព្រៃ។

ប្រាសាទត្រពាំងប្រើស ធ្លាប់មានការសិក្សាស្រាវជ្រាវជាច្រើនដោយជនជាតិបារាំង ដូចជា លោក Lunet De Lajonquire (ឆ្នាំ១៩០២), លោក M. Dufosse (ឆ្នាំ១៩១៨), លោក Henri Parmetier (ឆ្នាំ១៩៣៥)។ល។ ដោយសិក្សាស្រាវជ្រាវទៅលើសំណង់ស្ថាបត្យកម្មសិល្បៈ និងបានចុះបញ្ជីសារពើភណ្ឌប្រាសាទ។ រហូតមកដល់ឆ្នាំ២០០៨ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សហការជាមួយសាលាបារាំងចុងបូព៌ា បានចុះសិក្សាស្រាវជ្រាវ និងបានធ្វើបញ្ជីសារពើភណ្ឌទៅលើប្រាសាទនេះឡើងវិញ។ បច្ចុប្បន្ននៅ ជុំវិញបរិវេណប្រាសាទ អ្នកស្រុកបានសាងជាអាស្រមសំណង់ស្រាលមួយចំនួន តែពុំឃើញមាន ព្រះសង្ឃគង់នៅទីនោះឡើយ។ ដោយឡែកនៅទិសខាងកើតនៃប្រាសាទមានត្រពាំងធំមួយដែលអ្នកស្រុកតែងហៅថា "ត្រពាំងប្រើស" ដោយសារឈ្មោះត្រពាំងនេះហើយ ដែលជាមូលហេតុធ្វើឱ្យអ្នកស្រុកហៅប្រាសាទនេះតៗគ្នាថា "ប្រាសាទត្រពាំងប្រើស"។

អត្ថបទដោយ៖ លោក ម៉ង់ វ៉ាលី

ប្រាសាទត្រពាំងប្រើស ជាប្រាសាទមានតួប៉មចំនួនបី រត់ជាជួរពីទិសពាយព្យទៅអាគ្នេយ៍ សាងអំពីឥដ្ឋ បែរមុខទៅទិសឦសាន។ បើយើងពិនិត្យលើតួប៉មទាំងបី គឺមានរាងបួនជ្រុងទ្រវែង ក្នុងនោះតួប៉មកណ្ដាលមានប្រវែងបណ្ដោយ ៧.២០ម៉ែត្រ, ទទឹង ៥.៦០ម៉ែត្រ និងកម្ពស់ ១២ម៉ែត្រ ហើយតួប៉មនៅអមសងខាងមានប្រវែង ស្មើៗគ្នាដែលមានប្រវែងបណ្ដោយ ៦.៣០ម៉ែត្រ, ទទឹង ៥.៩០ម៉ែត្រ និងកម្ពស់ ១២ម៉ែត្រ។ ក្នុងចំណោមតួប៉មទាំងបីនេះ តួប៉មកណ្ដាលនៅមានសភាពល្អប្រសើរច្រើន ដោយតួប៉មពីរទៀតមានសភាពទ្រុឌទ្រោមខ្លាំង ដោយសារអាយុកាលនៃប្រាសាទ និងមានជនខិលខូចបានមកជីកបំផ្លាញរុករកវត្ថុបុរាណដែលជាហេតុធ្វើឱ្យរចនាសម្ព័ន្ធរបស់ប្រាសាទ ស្ទើរតែទាំងស្រុងបានបាក់រលំ។ តួប៉មទាំងបីនៃប្រាសាទសុទ្ធតែមានទ្វារចូលនៅទិសឦសាន ហើយមានទ្វារបញ្ឆោតនៅទិសផ្សេងទៀត ដែលទ្វារបញ្ឆោតនីមួយៗមានការលម្អជាក្បាច់រចនាផ្សេងៗ។ នៅផ្នែកខាងក្នុងតួប៉មពាយព្យ យើងបានប្រទះឃើញផ្ដែរទ្វារមួយបានរលំធ្លាក់បែកជាបួនបំណែកដែលមានលម្អជាក្បាច់រុក្ខជាតិផ្សេងៗមានលក្ខណៈជាសិល្បៈរចនាបថកំពង់ព្រះ។ បើទោះបីប្រាសាទនេះ មានលក្ខណៈទ្រុឌទ្រោមក៏ពិតមែន តែផ្នែកខ្លះនៃតួប៉មទាំងបីអាចឱ្យយើងនៅមើលឃើញយ៉ាងច្បាស់អំពីសិល្បៈនៃការឆ្លាក់ហោជាងនៃប្រាសាទ ដែលគេលម្អហោជាងជារាងដូចក្រចកសេះ និងផ្នែកខាងក្នុងមានចម្លាក់រាងដូចត្រីកោណចំនួនបី តម្រៀបគ្នា។ ហោជាងរបៀបនេះ ដូចគ្នាស្ទើរទាំងស្រុងជាមួយហោជាងនៅប្រាសាទព្រះធាតុព្រះស្រីនៅក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ រីឯសសរពេជ្រនៅប្រាសាទនេះ យើងរកឃើញគល់សសរចំនួនពីរបំណែកដែលគេយកមកទុកក្នុងសាឡុំមួយនៅខាងមុខប្រាសាទ ហើយគល់សសរពេជ្រនេះក៏មានលម្អជាក្បាច់ផ្សេងៗ ស្ទើរដូចនឹងសសរពេជ្រនៅប្រាសាទភូមិប្រាសាទ ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ។ ចំណែកសសរផ្ដោបគេគ្រាន់លម្អជាក្បាច់តិចតួចនៅគល់សសរប៉ុណ្ណោះ ហើយតួសសរផ្ដោបទាំងមូលមិនមានលម្អអ្វីឡើយ។

បើទោះបីជាប្រាសាទនេះ ពុំឃើញមានស្លាកស្នាមបន្សល់នៅសិលាចារឹកអ្វីក៏ពិតមែន តែក្នុងការសិក្សាប្រៀបធៀបកំណត់អាយុកាលសាកល្បងនៃប្រាសាទនេះ ពុំមានការលំបាកនោះឡើយ ដ្បិតទម្រង់ស្ថាបត្យកម្ម និងសិល្បៈនៃប្រាសាទត្រពាំងប្រើស មានលក្ខណៈស្រដៀងទៅនឹងប្រាសាទដែលស្ថិតនៅក្នុងរចនាបថកំពង់ព្រះ នាសតវត្សរ៍ទី៨ នៃគ្រឹស្ត

អត្ថបទដោយ៖ លោក ម៉ង់ វ៉ាលី

សកពរជ។ ជាងនេះទៅទៀត អ្វីដែលគួរកត់សម្គាល់នោះគឺ ប្រាសាទនេះស្ថិតនៅមិនឆ្ងាយពីក្រុងសម្ភុបុរទ្បើយ ពោល គឺស្ថិតនៅទិសខាងលិច មានចម្ងាយត្រឹមតែ ៣០គីឡូម៉ែត្រប៉ុណ្ណោះ។ ក្រុងសម្ភុបុរ គឺជាអតីតក្រុងបុរាណរបស់ខ្មែរមួយនាដើមសតវត្សរ៍ទី៨ ដល់ចុងសតវត្សរ៍ទី៨ ដែលគ្រប់គ្រងដោយព្រះមហាក្សត្រចំនួនបួនអង្គ គឺចាប់ផ្តើមដំបូងដោយព្រះបាទឥន្ទ្រលោក ហើយស្នងរាជដោយក្សត្រីចំនួនបីអង្គទៀតមានព្រះនាមថា ***នីពេន្ទ្រទេវី, ជយេន្ទ្រ----ភា, ជេស្ឋារ្យ*** ហើយសន្តិវង្សនេះមិនចំណុះឲ្យសន្តិវង្សខ្មែរកណ្តាលដែលគ្រប់ដោយព្រះនាងជ័យទេវីទ្បើយ។ ឈ្មោះក្រុង "សម្ភុបុរ" បានក្លាយទៅជាឈ្មោះស្រុកមួយនៃរដ្ឋបាលខេត្តក្រចេះគឺ "ស្រុកសំបូរ" ដ្បិតពាក្យសម្ភុបុរ គឺជាពាក្យសំស្ក្រឹតដែលមានន័យថាក្រុងនៃព្រះឥសូរ តែខ្មែរយើងមិនទម្លាប់អានស្រះខ្វីនោះទ្បើយ ក៏ក្លាយជាអានថា "សំបូរ" ដូចសព្វថ្ងៃនេះទៅ។ ប្រការនេះ នាំឱ្យយើងអាចសន្និដ្ឋានបានថា ប្រាសាទត្រពាំងប្រើស ទំនងសង់ទ្បើងនៅរវាងសតវត្សរ៍ទី៨ ក្នុងរជ្ជកាលក្សត្រីអង្គណាមួយនៅក្នុងចំណោមបីអង្គនេះ (ព្រះនាងនីពេន្ទ្រទេវី, ព្រះនាងជយេន្ទ្រ----ភា, ព្រះនាងជេស្ឋារ្យ) ដែលជាមហាក្សត្រគ្រប់គ្រងនៅក្រុងសម្ភុបុរ ដ្បិតស្ថាបត្យកម្ម សិល្បៈ មានលក្ខណៈដូចគ្នាខ្លាំងជាមួយបណ្តាប្រាសាទនៅក្នុងសម្ភុបុរ (ស្រុកសំបូរ ខេត្តក្រចេះ) ដូចជា ប្រាសាទព្រះធាតុក្វាន់ពីរ ហើយក៏ស្រដៀងប្រាសាទនៅខេត្តកំពង់ធំ និងកំពង់ឆ្នាំងដូចជា ប្រាសាទភូមិប្រាសាទ ប្រាសាទសក្ក ប្រាសាទព្រះស្រី ។ល។ ពោល គឺត្រូវគ្នានឹងសិល្បៈខ្មែរក្នុងរចនាបថកំពង់ព្រះ ស.វ.ទី៨ នៃគ.ស.។





អត្ថបទដោយ៖ លោក ម៉ង់ រ៉ាលី













អត្ថបទដោយ៖ លោក ម៉ង់ វ៉ាលី